# ការសំភាសន៍របស់អ៊ុំប្រុស អឿន ឈន

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ អឿន ឈន

**<u>ការសង្ខេបប្រវត្តិរបស់ អ៊ុំប្រុស អឿន ឈន</u>**

អ៊ុំប្រុស អឿន ឈន មានអាយុ58ឆ្នាំ នៅក្នុងឆ្នាំ2018 អ៊ុំប្រុស អឿន ឈន មានភេទប្រុស អ៊ុំប្រុស អឿន ឈន មានទីលំនៅបច្ចុប្បន្ននៅ ភូមិព្រែកថ្លឹង សង្កាត់ជើងឯក ខណ្ឌដង្កោ នៅរាជធានីភ្នំពេញ។

កៈ
ចឹងជាដំបូងខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយយាយដែរទាក់ទងពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU
ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ
ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់
បានស្គាល់នឹងបានដឹងពីប្រវត្តិរបស់ឪពុកម្តាយនឹង
ប្រវត្តិរបស់ដូនតាចឹងហើយនៅពេលដែរខ្ញុំបានសំភាសន៍អ៊ុំ
ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu
ចឹងសំរាប់អ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ ដាក់ចុះអូនអត់អីទេ

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍អ៊ុំគឺនៅថ្ងៃទី25ខែ4 ឆ្នាំ2018 មួយនឹងនៅភូមិអីគេដែរអ៊ុំ?

ខៈ ភូមិព្រែកថ្លឹង

កៈ ភូមិព្រែកថ្លឹង?

ខ៖ សង្កាត់ជើងឯក

ក៖ នៅសង្កាត់ជើងឯក នៅខណ្ឌ័?

ខ៖ ខ័ណ្ឌដង្កោ

ក៖ នៅរាជធានីភ្នំពេញ?

ខ៖ បាទៗ!!

ក៖ ចឹងសំរាប់អ៊ុំមានឈ្មោះពេញឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖ មានឈ្មោះ អឿន ឈន

ក៖ ឈ្មោះ អឿន ឈន ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖ ហៅក្រៅនឹងគេហៅអាដំណើប

ក៖ ហៅអាដំណើបណអ៊ុំ?

ខ៖ បាទ!!

ក៖ ចុះកាលពីក្មេងនឹងធ្លាប់មាននរណាគេហៅឈ្មោះអ៊ុំអីផ្សេងដែរទេអ៊ុំ?

ខ៖ អត់ទេ

ក៖ អត់ទេណអ៊ុំ ចុះសព្វថ្ងៃអ៊ុំអាយុប៉ុន្មានដែរទៅ?

ខ៖ ខ្ញុំអាយុ58ឆ្នាំ

ក៖ អ៊ុំអាយុ58ឆ្នាំចុះអ៊ុំមានចាំថាអ៊ុំកើតនៅថ្ងៃខែឆ្នាំណាទេអ៊ុំ?

ខ៖ អត់

ក៖ អត់ទេណ ថ្ងៃខែក៏អ៊ុំអត់ចាំដែរណ?

ខ៖ បាទ!!

ក៖ ចឹងអ៊ុំអាយុ58ឆ្នាំ ចឹងអ៊ុំកើតនៅឆ្នាំ1960មែនអត់អ៊ុំ?

ខ៖ បាទៗ!!

កៈ បាទអ៊ុំកើតនៅណាដែរអ៊ុំ?

ខៈ នៅភូមិព្រែកថ្លឹង

កៈ អ៊ុំកើតនៅភូមិនឹងតែម្តងហោសអ៊ុំ?

ខៈ បាទ!!ខ្ញុំកើតនៅព្រែកថ្លឹងនឹងនោះអានេះខ្ញុំទើបតែបង្កើតមកថ្មីទេអានេះហោស

កៈ អ៎ូ!!ភូមិព្រែកថ្លឹង ឃុំអីគេដែរអ៊ុំ?

ខៈ នៅសង្កាត់ជើងឯក ខ័ណ្ឌដង្កោ

កៈ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញនឹង?

ខៈ បាទ!!

កៈ បាទ!!ចុះអ៊ុំឆ្នាំខ្មែរអ៊ុំឆ្នាំអីគេដែរអ៊ុំឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខៈ ខ្ញុំឆ្នាំកុល

កៈ អ៊ុំឆ្នាំកុលណាអ៊ុំណា?

ខៈ បាទ!!

កៈ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ទៅអ៊ុំ?

ខៈ មួយ ពីរ បី មានបួននាក់

កៈ មានបួននាក់ណាអ៊ុំ?

ខៈ បាទ!!

កៈ ប៉ុន្តែអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំបងគេ

កៈ មានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ទៅអ៊ុំ?

ខៈ មានស្រីពីរ នឹងប្រុសពីរ

កៈ ចុះអ៊ុំអាចប្រាប់ឈ្មោះបងប្អូនរបស់អ៊ុំបានទេ ថាពួកគាត់មានឈ្មោះអីគេខ្លះដែរទៅ?

ខៈ មានឈ្មោះសីន មួយ ឈ្មោះសាល់មួយ ស្រីៗៗប្រុសឈ្មោះឈឿន ហើយខ្ញុំឈ្មោះឈន

កៈ ប៉ុន្តែអ៊ុំបងគេ?

ខៈ បាទ!!អូមាន៥នាក់ហោសនៅមានម៉ែមួយទៀត

កៈ មាន៥នាក់ណាអ៊ុំណា?

ខៈ បាទៗៗ!!

កៈ ចុះអ៊ុំមានចងចាំថាកាលពីនៅក្មេងអ៊ុំធ្លាប់បានលេងអីជាមួយបងប្អូនរបស់អ៊ុំទេ ដូចលក្ខណៈថាលេង បិទពួនអីចឹងហាស?

ខៈ អ៊ូ!!ខ្ញុំនៅផ្ទះឆ្ងាយពីគេហាសអូន ខ្ញុំនៅផ្ទះឆ្ងាយពីភូមិចឹងនៅឆ្ងាយពីគេណាស់គ្មានគ្នាលេងទេម្នាក់ឯង

កៈ ប៉ុន្តែលេងជាមួយបងប្អូនរបស់អ៊ុំដែរហើអ៊ុំ?

ខៈ បាទ!!មានតែបងប្អូននឹងបងប្អូនបង្កើតខ្ញុំនឹង

កៈ បាទ!!ភាគច្រើនអ៊ុំចូលចិត្តធ្វើអីគេជាមួយពួកគាត់ដែរទៅ?

ខៈ ខ្ញុំវាក្រពេកដល់ចឹងអត់បានធ្វើអីទេជួនម៉ែមកស្ទូងដកអោយគេចឹងទៅ ខ្ញុំទៅបាចត្រីបាចអីចឹងទៅយកមកធ្វើម្ហូបអោយប្អូនហូបចឹងទៅណាស់

កៈ អ៊ូ!!បាទអ៊ុំបាទ ចុះអ៊ុំគិតថាប្អូនៗៗរបស់អ៊ុំនឹងសព្វថ្ងៃគាត់នៅណាអ៊ុំ?

ខៈ នៅភូមិព្រែកថ្លឹងទាំងអស់

កៈ ទាំងអស់គ្នានឹងហោសអ៊ុំ?

ខៈ បាទ!!

កៈ ប៉ុន្តែពួកគាត់អីគេដែរអ៊ុំសំរាប់ចិញ្ចឹមក្រុមគ្រួសារហោស?

ខៈ គាត់ធ្វើជាកម្មករគេដែរនឹង

កៈ ទាំងអស់គ្នាតែម្តងហោសអ៊ុំ?

ខ៖ បាទ!!

ក៖ គាត់ធ្វើកម្មករគាត់ធ្វើអីគេនៅណុាង?

ខ៖ គាត់ធ្វើកម្មករសំណង់

ក៖ អូ៎!!

ខ៖ ធ្វើអីចឹងទៅ

ក៖ បាទ!!អ៊ុំបាទ ចុះឪពុករបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឈ្មោះពន់ អឿន

ក៖ ចុះគាត់ប្រហែលជាអាយុប៉ុន្មានដែរអ៊ុំដល់ឥឡូវនឹង?

ខ៖ អើរជំណើរអាយុប៉ែតជាងអស់ហើយគាត់

ក៖ ប៉ុន្តែគាត់នៅរស់តើហី?

ខ៖ គាត់ស្លាប់អស់ហើយ

ក៖ អូ៎!!ប៉ុន្តែអ៊ុំមានដឹងថាគាត់កើតនៅណាទេឪពុករបស់អ៊ុំហាស?

ខ៖ កើតនៅភូមិនឹងដែរ

ក៖ ចឹងហោសអ៊ុំ?

ខ៖ កើតនៅភូមិព្រែកថ្លឹងនឹង

ក៖ ចុះម្ដាយរបស់អ៊ុំវិញ?

ខ៖ កើតនៅព្រែកថ្លឹងនឹងដែរ

ក៖ ប៉ុន្តែគាត់មានឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖ គាត់ឈ្មោះ ម៉ក ណម

ក៖ គាត់នឹងតាគាត់ខុសគ្នាប៉ុន្មានឆ្នាំដែរអ៊ុំ ប្អូនគ្នាប៉ុន្មានឆ្នាំទៅ?

ខ៖ អត់បានដឹងទេអានឹង

កៈ ចឹងហោសអ៊ុំ ចុះតាកាលពីគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ តាខ្ញុំពីដើមមកគាត់ហៅថាគាត់ធ្វើគ្រូ

កៈ គ្រូបង្រៀនហោសអ៊ុំ?

ខៈ គ្រូមើលអ្នកឆ្កួត

កៈ អូ៎!!

ខៈ មើលឡានគេតែអាអេចនោះជិតអត់កើតផង
ប្រាប់អូនឯងនៅសម័យនេះអូនឯងទៅជឿអីអូនឯងនឹង អត់មានជឿទេ

កៈ បាទ!!

ខៈ ទូកក៏ជិះអត់កើតដែរ

កៈ អូ៎!!

ខៈ ឡានអាកងទ័រន័រអាធំៗៗនឹងក៏ជិះអត់កើតដែរជិះអត់កើតដែរ

កៈ អូ៎!!តែគាត់ធ្វើនឹងគឺគាត់ធ្វើអត់អោយជិះអត់កើតហោសអ៊ុំ?

ខៈ អត់ទេជិះអត់កើតតែម្តង

កៈ អូ៎!!លក្ខណៈចង់ឡើងជិះប៉ុន្តែជិះអត់កើតមែន?

ខៈ គាត់មានមហាទំងន់

កៈ អូ៎!!

ខៈ ដើមត្នោតនេះមួយដៃដដាច់កលើហោស

កៈ អូ៎!!ឡូយម៉េសអ៊ុំ?

ខៈ ដឹងអីអានឹងខ្ញុំមិនដឹងដែរគាត់

កៈ អានឹងកាលចាស់ៗៗពីដើមមែនទេអ៊ុំ?

ខៈ បាទ!!គាត់ចាស់បុរាណ មនុស្សបុរាណតែម្តងនឹង

កៈ ប៉ុន្តែមិនមានតែគាត់មួយទេអ្នកផ្សេងក៏គេចេះដែរណាអ៊ុំ?

ខៈ អត់ទេនៅក្នុងភូមិនឹងមានឃើញតែថាខ្ញុំនឹងមួយ

កៈ អូ៎!!គាត់ឡូយហាសអ៊ុំ
អានឹងគាត់ធ្វើមុខរបរមួយនឹងដើម្បីចិញ្ចឹមក្រុមគ្រួសារនឹងចិញ្ចឹមជីវិត?

ខៈ គាត់អត់សួរចង់បានលុយពីគេផង

កៈ អូ៎!!

ខៈ គាត់ឃើញគេឆ្កួតចឹងគាត់យកគេមកមើលចឹង គាត់ដាំទឹកពុះៗៗនឹង

កៈ បាទ!!

ខៈ ទឹកកំពុងតែពុះនឹងគាតដាំចាក់លើមនុស្សនឹង

កៈ បាទ!!អូ៎?

ខៈ គាត់ស្រោចទឹក

កៈ អូ៎!!ឡូយម៉េសអ៊ុំប៉ុន្តែ?

ខៈ អូនឯងចង់ដើរមួយយប់ទល់ភ្លឺតែស្រែមួយនោះក៏បានដែរ

កៈ អូ៎!!ម៉េចចឹងអ៊ុំ?

ខៈ
ចឹងបានថាអូនឯងអត់ជឿទេប្រាប់អូនឯងនឹងអូនឯងអត់ជឿទេមនុស្សពីដើមនោះគឺមនុស្សដើមពិត
ប្រាកដយើងនិយាយទៅខ្ញុំនិយាយទៅអូនឯងអត់អាចជឿបានទេតែបើការពិតអានឹងវាមានការពិត មានចាស់នៅក្នុងភូមិនឹងទៅសួរទៀត

កៈ បាទ!!បាទអ៊ុំ?

ខៈ ថាវាមែនរឺមួយក៏លេង

កៈ បាទ!!អ៊ុំបាទអូចឹងអស្ចារ្យហាសណាអ៊ុំ?

ខៈ បាទៗៗ!!

កៈ ប៉ុន្តែដូចជាឪពុករបស់អ៊ុំគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខៈ អត់គាត់ស្លូតដែរតែថាគាត់កាចក៏ថាបានគាត់អ្នកលេងល្បែន

កៈ អូ៎!!

ខៈ ពីដើមមកទាល់តែសួរឪពុកអូនបានស្គាល់មានតាយន្ត មានចេកម៉ាចអីចឹងទៅណាស់

កៈ បាទៗៗ!!អ៊ុំបាទ?

ខៈ គាត់បានដឹង

កៈ ជំនាន់ពួកខ្ញុំនៅក្មេងៗៗពេកណាអ៊ុំ?

ខៈ បាទ!!

កៈ ចុះអ៊ុំគិតថាម្តាយរបស់អ៊ុំនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ អូ៎!!ក្រប្រាប់ថាក្រហើយអាអូនតាខ្ញុំអីចឹងគាត់មានតែថាបន្តអស់ពីតាទៅនោះ

កៈ បាទ!!អ៊ុំ?

ខៈ គាត់ធ្លាក់ខ្លួនទៅក្រគេហៅថាមនុស្សចិញ្ចឹមខ្មោចនឹងគឺអត់ល្អទេអាអូនអើយ

កៈ បាទ!!អ៊ុំបាទ?

ខៈ ដល់ចឹងគាត់ក្រគាត់ដើរស្នូង
ដកអោយគេចឹងទៅខ្ញុំឪអីចឹងរកត្រីចឹងលក់ដូរអីចឹងយកមកដូរអង្ករអី ហូបចឹងទៅណាស់

កៈ ប៉ុន្តែអ៊ុំទៅជាមួយគាត់ដែរចឹងទៅទៅជួយធ្វើគាត់ទៅ?

ខៈ បាទ!!ខ្ញុំទៅខ្ញុំទៅជាមួយឪពុក

កៈ អូ៎!!បាទចុះម្តាយរបស់អ៊ុំគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខៈ គាត់ស្លូត

កៈ គាត់ស្លូតដែរណាអ៊ុំណា?

ខ៖ បាទ!!មួយភូមិនឹងស្រលាញ់គាត់ទាំងអស់រាប់ភូមិហោសបីបួនប្រាំភូមិហោស

ក៖ បាទ!!
អុំចុះអុំមានចងចាំថាកាលពីអុំនៅជាមួយឪពុកម្តាយអុំនឹងដូចជាអុំធ្លាប់ធ្វើការងារអីដែរអុំចាំ
អត់ ភ្លេចដែរជាអនុស្សាវរីយ៍ជាមួយឪពុកម្តាយរបស់អុំហាស?

ខ៖ ខ្ញុំចង់ចាំនៅជាមួយឪពុកម្តាយរបស់ខ្ញុំ
គាត់ក្រមែនពិតតែខ្ញុំមិនអោយនរណាមើលងាយគាត់ ខ្ញុំចងចាំប៉ុណ្ណឹង

ក៖ អូ៎!!ចឹងណាអុំ?

ខ៖ អត់អត់មានគេមើលងាយគាត់ទេពីព្រោះគាត់អត់មានទៅធ្វើអីមួយអោយខុសហាស

ក៖ បាទ!!អុំបាទ?

ខ៖ និយាយភាសាខ្មែរថាអត់មានធ្វើអីខុសហាស

ក៖ អូ៎!!បាទអុំ?

ខ៖ គេអាណិតគេស្រលាញ់គេអោយអង្ករអីចឹងទៅ
ទៅច្រូតអោយគេចឹងទៅខ្លះគេអោយលុយ ខ្លះគេអោយអង្ករចឹងទៅ

ក៖ បាទ!!អុំបាទ?

ខ៖ យកមកចិញ្ចឹមជីវិត

ក៖ ចុះឪពុករបស់អុំគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអុំទេ?

ខ៖ អត់ទេដូចជាអត់ដែរប្រាប់ គ្រាន់តែគាត់ប្រដៅខ្លះថាកូនអើយអំពើល្អ

ក៖ ធ្វើល្អបានល្អណអុំ?

ខ៖ បានទៅជាព្រះ អាអំពើអាក្រក់នឹងវាបានទៅជាមា

ក៖ បាទ!!អុំបាទ?

ខ៖ ពាក្យពីរនឹងកូនយកទៅគិតទៅ

ក៖ អូ៎!!ត្រូវហើយអុំ?

ខ៖ នឹងហើយ

ក៖ ចុះម្ដាយរបស់អ៊ុំវិញគាត់មានដែរប្រាប់អីទៅអ៊ុំទេ កាលពីគាត់នៅក្មេងអីចឹងបាស?

ខ៖ គាត់អត់មានប្រាប់អីទេ
គាត់ប្រាប់ដូចតែឪពុកខ្ញុំដែរចឹងនឹងកាលណាយើងមានសិល្ប៍៥នៅក្នុងខ្លួន
មនុស្សដើរទៅណាក៏គេដើរអាណិតស្រលាញ់ដែរពីព្រោះពាក្យថាសិល្ប៍៥ៗៗម្នាក់ៗៗទៅ
មានចេះអាណិតគេ ដូចថាអ្នកសុំទាន រឺមួយក៏អ្នករើសអេតចាយ

ក៖ បាទ!!អ៊ុំបាទ?

ខ៖ បើអ្នកធ្វើអីមួយយើងទៅកុំរើសអើងនឹងគ្នាពីព្រោះមនុស្សដូចគ្នាទេ
គ្រាន់តែគ្នាគ្មានខួរក្បាលគ្រប់

ក៖ បាទអ៊ុំបាទត្រូវ?

ខ៖
ដល់ចឹងខ្ញុំក៏ធ្វើចឹងតាមគាត់ខ្ញុំក៏ដើរទៅជូនណាតែមុខផ្ទះខ្ញុំនឹងជូន៥ពាន់១ម៉ឺនមកអោយ

ក៖ បាទ!!អ៊ុំបាទចុះ?

ខ៖ ខ្ញុំធ្លាប់ក្រចឹងខ្ញុំដឹង

ក៖ បាទ!!ចុះយាយតាខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ទេ?

ខ៖ អើរភ្លេចអស់ហើយអាអូនអើយនៅស្គាល់ខ្លះបើថាតា ឈ្មោះតាម៉ក់

ក៖ ចុះយាយអ៊ុំ?

ខ៖ យាយនឹងឈ្មោះយាយណៃ

ក៖ ចុះយាយតាខាងម្ដាយវិញអ៊ុំ?

ខ៖ ខាងម្ដាយនឹងឈ្មោះម៉ក់ ណម ឈ្មោះម៉ក់ ណមមិញនឹងខាងម្ដាយ
ហើយបើឪពុកឈ្មោះអ៊ុន

ក៖ នឹងតា?

ខ៖ តាខាងឪរបស់ខ្ញុំ

ក៖ បាទចុះយាយឈ្មោះអីគេដែរអ៊ុំ យាយខាងឪពុកវិញ?

ខ៖ អត់ស្គាល់ទេ

ក៖ អយត់ស្គាល់ទេហោស ចុះអ៊ុំមករស់នៅនឹងយូរនៅអ៊ុំ?

ខ៖ មើលខ្ញុំមកនេះនៅនេះចូល២០ឆ្នាំហើយនេះខ្ញុំមកពីភូមិមក

ក៖ អូ!!ចឹងអ៊ុំ?

ខ៖ ភូមិនេះមកនឹងអត់មានមនុស្សផងនឹងមានតែខ្ញុំនឹងតើ!!

ក៖ អូ!!ទើបតែគេបង្កើតក្រោយទេភូមិនឹងហោសអ៊ុំ?

ខ៖ ខ្ញុំទើបតែបង្កបង្កើតនឹងមួយជួរនឹងសុទ្ធតែផ្ទះខ្ញុំតើនឹង

ក៖ អូ!!បាទអ៊ុំបាទ?

ខ៖ នៅក្រោយណុងទៀត

ក៖ ចុះអ៊ុំមានបងប្អូនរឺមួយក៏កូនចៅណាដែរទៅរស់នៅក្រៅប្រទេសទេអ៊ុំ?

ខ៖ អត់ទេ

ក៖ ទៅថៃ វៀតណាមអីទៅធ្វើការអីក៏អត់ដែរណាអ៊ុំ?

ខ៖ អានឹងក៏អត់ដែរអត់ទេ

ក៖ អូ!!ចុះដូចជាភរិយារបស់អ៊ុំនឹងឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឈ្មោះ សេង វ៉ាន

ក៖ អូ!!អ៊ុំស្រីនៅក្រោយណា?

ខ៖ បាទ!!

ក៖ អូ!!អ៊ុំបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរអ៊ុំមានចងចាំទេ?

ខ៖ ខ្ញុំភ្លេចអស់ហើយ

កៈ អូ៎!!ប៉ុន្តែ?

ខៈ វាយូរដែរហើយខ្ញុំមានការបាត់បង់ខ្ញុំឆ្កួតមួយសារហើយ ដឹងតែឆ្នាំកុល

កៈ នៅឆ្នាំកុលណាអ៊ុំណា?

ខៈ បាទៗៗ!!នឹង

កៈ ប៉ុន្តែអ៊ុំ?

ខៈ ពីព្រោះអីខ្ញុំធ្លាប់ឆ្កួតមួយដងហើយនឹងហាស

កៈ អូ៎!!ចឹងហោសអ៊ុំ?

ខៈ បាត់បង់ម្តងហើយខ្ញុំស្មានតែខ្ញុំមិនបានប៉ុណ្ណឹងវិញផងនឹង

កៈ ប៉ុន្តែដូចជាកូនបងរបស់អ៊ុំនឹងគាត់អាយុប៉ុន្មានដែរឥឡូវនឹងអ៊ុំ?

ខៈ អាយុសាមជាង សាមជាងក្បែរសែហើយអាបងនឹង

កៈ អូ៎!!ចឹងមានន័យថាអ៊ុំការខ្ទង់ជាងសែសិបឆ្នាំហើយណាអ៊ុំ?

ខៈ បាទ!!

កៈ ចុះសំរាប់ដូចជានៅពេលដែរអ៊ុំបានរៀបអាពាហ៍ពិពាហ៍ជាមួយអ៊ុំស្រីនឹង គិតថាចិត្តជាអ្នកចង់រៀបចំដោយខ្លួនឯងរឺមួយក៏ឪពុកម្តាយជាអ្នករៀបចំអោយដែរអ៊ុំ?

ខៈ ឪពុកម្តាយ

កៈ ឪពុកម្តាយជាអ្នករៀបចំអោយណាអ៊ុំ?

ខៈ បាទៗៗ!!

កៈ ចុះអ៊ុំគិតថាមានជាជំនូនជូនទៅអ៊ុំស្រីទេពេលជំនាន់ណុងហាសអ៊ុំ?

ខៈ មានដែរនឹង

កៈ ប៉ុន្តែពេលណុងគេជូនលក្ខណៈថាជារបស់របរតើហីអ៊ុំ ពេលណុងគេមិនទាន់ជូនជាលុយណាហីអ៊ុំ?

ខ៖ អោយចិញ្ច្រៀន

ក៖ អ្ហ៎!!គេអោយចិញ្ច្រៀនដែរហោសអ៊ុំ?

ខ៖ បាទ!!អោយជាចិញ្ច្រៀនមួយវង្សអានឹងឧបម៉ាថាយើងមានទេណាអូនណា

ក៖ បាទ!!អ៊ុំបាទ?

ខ៖ នឹងខ្ញុំរកខ្ញុំធ្វើចឹងទៅ

ក៖ អ្ហ៎!!

ខ៖ គេអត់យកទេដី

ក៖ អ្ហ៎!!ចុះអ៊ុំធ្លាប់បានរៀនទេអ៊ុំពីមុន?

ខ៖ អត់តែម្ដង

ក៖ អត់ដែរបានរៀនទេណាអ៊ុំ?

ខ៖ រៀនណាបើយើងក្រពេកហើយនិយាយថាខ្ញុំមិនមែនក្រទេខ្ញុំទាល់តែម្ដង

ក៖ អ្ហ៎!!បាទ?

ខ៖ ជីវិតរបស់ខ្ញុំនឹងវាហួសពីក្រទៀតនឹងហាស

ក៖ បាទ!!អ៊ុំបាទ?

ខ៖ ដល់ចឹងខ្ញុំហត់ណាស់

ក៖ ចុះសំរាប់អ៊ុំគិតថាអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរយើងទេអ៊ុំ?

ខ៖ ចេះតែភាសាខ្មែរនឹង

ក៖ អ្ហ៎!!បាទអ៊ុំ
ចុះអ៊ុំធ្លាប់មានមិត្តភក្តិដែរស្និទ្ធិស្នាលធំធាត់មកជាមួយគ្នាដែរទេអ៊ុំចឹងពីមុនហាស?

ខ៖ មានពីរនាក់មួយនៅគៀនស្វាយឥឡូវនឹងកំពុងអោយគេផ្សាយរកដែរអាណិត
នឹកឃើញគ្នាបាត់គ្នាចឹងទៅណាស់នឹក

កៈ នឹងបាត់តាំងពីពេលណាដែរអ៊ុំ?

ខៈ មើលខ្ញុំអាយុ៨៣ឆ្នាំខ្ញុំធ្វើជាទាហ៊ាននៅឃោធាខេត្តកណ្តាលតែម្តង

កៈ បាទ!!អ៊ុំ?

ខៈ គេអោយធ្វើស្មៀនហាសអូនតែអ៊ុំអត់ចេះអក្សរ

កៈ ប៉ុន្តែមិត្តភក្តិរបស់អ៊ុំដែរស្និទ្ធិស្នាលនឹងពួកគាត់មានឈ្មោះអីគេអ៊ុំមានចងចាំទេ?

ខៈ អាមួយនៅគៀនស្វាយនឹងឈ្មោះសាង ហេង

កៈ ចុះមួយទៀតនឹងនៅណាទៀអ៊ុំ?

ខៈ ឈ្មោះផល្លីនៅជើងឯក

កៈ អូ៎!!

ខៈ នៅខ័ណ្ឌដង្កោនឹង

កៈ ប៉ុន្តែនៅជិតអ៊ុំនឹងទេ?

ខៈ បាទ!!អានឹងស្គាល់

កៈ បាទ!!អ៊ុំបាទ?

ខៈ បើអាមួយទៀតនឹងខ្ញុំរកអត់ឃើញទេឥឡូវនឹង

កៈ ប៉ុន្តែអ៊ុំធ្លាប់មានចាំអនុស្សាវរីយ៍អីដែរអ៊ុំធ្លាប់នៅរឺធ្លាប់ធ្វើការជាមួយគាត់
រឺក៏ដើរលេងជាមួយគាត់អ៊ុំធ្លាប់ចាំទេរឺធ្លាប់ធ្វើអីជាមួយគាត់ចឹងហាសអ៊ុំមានចាំទេ?

ខៈ មានតែធ្វើទាហ៊ាននឹងធ្វើទាហ៊ានយើងដើរ
មើលតាមប៉ុស្តិ៍តាមអីគេគេអោយយើងដើរពីក្បាលថ្នល់ចឹង ទៅរហូតដល់

កៈ តាខ្មៅហោសអ៊ុំ?

ខៈ រហូតដល់តាកែវអីចឹងហោស

កៈ អូ៎!!ចឹងហោសអ៊ុំឆ្ងាយហាសណាអ៊ុំ?

ខ៖ បាទ!!

ក៖ នឹងយើងដើរទៅខ្លួនឯងតែម្ដងនឹង?

ខ៖ កាលណុងគេនៅប្រកាសអាសន្នអូនឯងនៅមិនទាន់កើតផងទេ

ក៖ បាទ!!នៅទេអ៊ុំ?

ខ៖ បាទ!!គេប្រកាសអាស្នប្រកាសអីគេហោសមិនទាន់ទេ

ក៖ ដោយសារតែខ្ញុំកើតឆ្នាំកៅជាងហើយនឹងអ៊ុំ?

ខ៖ អត់ទេអត់ទាន់ទេ

ក៖ បាទ!!

ខ៖ នៅឆ្នាំ១៩៨៣

ក៖ ចុះអ៊ុំគិតថាឥឡូវនឹងមិត្តភក្ដិរបស់អ៊ុំនៅបែកគ្នាឆ្ងាយៗអស់ហើយណា?

ខ៖
នៅឆ្ងាយតែអានេះចេះតែនឹកទៅដែរនឹងអាឥឡូវនឹងអត់ទាន់បានទៅផងនឹងកាលពីមុនទៅអោយ ២០$ចឹងហាស

ក៖ អូ៎!!ជីវភាពពួកគាត់រៀងយ៉ាប់ដែរហោសអ៊ុំ?

ខ៖ អត់ៗយ៉ាប់

ក៖ អូ៎!!បាទអ៊ុំចុះអ៊ុំធ្លាប់ទៅធ្វើការនៅវាលស្រែចំការទេអ៊ុំ?

ខ៖
ហើនិយាយពីស្រែចំការនឹងវាឆ្អែតតែម្ដងនឹងអូនដូចថាដីវាខ្វះប៉ុន្មាន១០ហត្ថាដែរនឹងហាស

ក៖ បាទ!!អ៊ុំ?

ខ៖ ដល់ចឹងយើងធ្វើម្នាក់ឯងភ្ជួរផង ព្រុះផងកាប់ព្រៃផង

ក៖ អានឹងអ៊ុំធ្វើនៅស្រែណាអ៊ុំណា?

ខ៖ បាទ!!នៅស្រែ

កៈ ចុះអ៊ុំគិតថាអ៊ុំធ្លាប់លក់ដូរអីមួយបង្កើតអាជីវកម្មអីមួយទេអ៊ុំ?

ខៈ ធ្លាប់ដឹកត្រីលក់

កៈ ធ្លាប់ដឹកត្រីលក់ហោសអ៊ុំ?

ខៈ បាទ!!ខ្ញុំឈប់រកធ្វើអានេះម្ដង

កៈ ប៉ុន្តែអ៊ុំដឹកត្រីលក់នៅណាដែរអ៊ុំ?

ខៈ ដឹកពីនឹងយកទៅលក់នៅអូឡាំពិច

កៈ អូ៎!!

ខៈ បាទ!!នៅផ្សារដើមគរ អូរឬស្សី

កៈ អ៊ុំទៅរកមកខ្លួនឯងតែម្ដងមែនអ៊ុំ?

ខៈ ទិញគេខ្លះរកខ្លួនយើងខ្លះ

កៈ បាទ!!អ៊ុំបាទ ចុះអ៊ុំគិតថាអ៊ុំធ្លាប់ចិញ្ចឹមសត្វទេពីមុនហាស ដូចជាមាន់ ទា ជ្រូក គោ ក្របីអីចឹងហាស?

ខៈ ធ្លាប់ចិញ្ចឹមគោ ទា មាន់

កៈ ប៉ុន្តែមួយនឹងអ៊ុំចិញ្ចឹមជាលក្ខណៈគ្រួសារមួយក៏កសិដ្ឋានដែរអ៊ុំ?

ខៈ ខ្ញុំកសិដ្ឋានដែរនឹងហាស

កៈ អូ៎!!ចិញ្ចឹមច្រើនណាអ៊ុំ?

ខៈ បាទ!!មានគេធ្លាប់មកសំភាសន៍ម្ដងហើយ

កៈ បាទ!!អ៊ុំ
ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្ដូរអីគេខ្លះដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាសពីក្មេងមានការផ្លាស់ប្ដូរអីដល់ឥឡូវនឹងចឹងហាសអ៊ុំ?

ខៈ ខ្ញុំផ្លាស់ប្ដូរដូចចេះអូនពីព្រោះពីមុនមកនឹងយើងក្មេង
យើងចេះតែធ្វើអាជីវកម្មនឹងហាសអូនណាស់

កៈ បាទ!!អ៊ុំបាទ?

ខៈ
សត្វធាតុនឹងចឹងដល់ពេលប៉ុន្មានឆ្នាំនេះខ្ញុំវាចាស់ទៅខ្ញុំចឹងខ្ញុំគិតថាភាសាខ្មែរគេនិយាយថាចូលអាធំមកាន់សិល្ប៍ហាអូនណាស់

កៈ បាទ!!អ៊ុំបាទត្រូវ?

ខៈ បាទ!!ដល់ពេលចឹងខ្ញុំសំរាក់ការងារនឹងធ្វើបុណ្យធ្វើទានម្តងចឹងទៅចឹងហាស

កៈ បាទ!!ត្រូវហើយអ៊ុំ?

ខៈ បាទ!!

កៈ
ចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់ដែរអ៊ុំ ដូចថាពីក្មេងធ្លាប់ធ្វើអីគេ ហើយឥឡូវនឹងធ្លាប់ធ្វើអីគេចឹងហាសអ៊ុំ?

ខៈ ខ្ញុំពីឆ្នាំ១៩៧៩ទៅ១៩៨០នឹងធ្លាប់រត់កង់ឌុប ហើយកង់ឌុបនឹងគេលែងជិះចឹងទៅ
យើងទៅទិញអាទៅសួរតែប៉ាអូនឯងនឹងដឹងហើយទិញចេញមកអាកៅ
គេហៅអាម៉ូតូអាកៅអាកន្ដោអាអីនឹងហាសចេញមករត់ឌុបទៀតទៅ

កៈ មួយនឹងផ្ទះរបស់ខ្ញុំក៏ធ្លាប់មានដែរអ៊ុំ

ខៈ បាទ!!អ្ហូ!!នឹងហើយៗ

កៈ បាទ!!

ខៈ ទិញអានឹងមកបានរត់ម៉ូតូឌុបរត់អីចឹងទៀតទៅ

កៈ អ្ហូ!!បាទ?

ខៈ ហើយយើងធ្វើអាជីវកម្មដឹកត្រីដឹកអីខ្លះផង

កៈ បាទ!!អ៊ុំចុះអ៊ុំគិតថាម្ហូបអីដែរអ៊ុំចូលចិត្តពិសារដែរអ៊ុំ?

ខៈ អ្ហូ!!សម្លម្ជូរនឹងហាស ខ្ញុំក្រៅពីមើលទៅដូចជាពិបាកនិយាយណាស់អូនអើយ

ក៖ ម៉េចចឹងអ៊ុំ?

ខ៖
ថាសាច់នឹងជូនកាលគេដាក់ទៅមាន៥ទៅ៦មុខហើយនោះរាល់ថ្ងៃតែខ្ញុំហូបអត់កើតខ្ញុំអត់
លូកតែម៉ង

ក៖ ម៉េចចឹងអ៊ុំ?

ខ៖ អត់អត់ឃ្លាន បើប្រហុកចិញ្ច្រាំឆៅ សំលម្ជូរអីនឹងខ្ញុំហូប

ក៖ អូ្វ!!អ៊ុំចូលចិត្តចិញ្ច្រាំប្រហុកឆៅ នឹងសម្លម្ជូរអីចឹងហោសអ៊ុំ?

ខ៖ បាទ!!

ក៖ ចុះអ៊ុំគិតថាកាលពីក្មេងអ៊ុំធ្លាប់លេងល្បែងប្រជាប្រិយ៍អីខ្លះដែរអ៊ុំ?

ខ៖ លេងឈូង បោះអង្គុញអី

ក៖ អូ្វ!!ចឹងណាអ៊ុំ?

ខ៖ បាទ!!

ក៖ ភាគច្រើនទៅលេងនៅវត្តអីចឹងណា?

ខ៖ លេងនៅភូមិនឹងតែម្តងនឹង

ក៖ បាទ!!អ៊ុំចេះច្រៀងទេអ៊ុំ?

ខ៖ អត់ចេះទេ

ក៖ អូ្វ!!អត់ចេះទេហោសអ៊ុំ?

ខ៖ បាទ!!អត់ចេះទេ

ក៖ ប៉ុន្តែអ៊ុំចូលចិត្តស្តាប់បទចំរៀងអីតើហីពីមុនអី?

ខ៖ នោះធុងបាសខ្ញុំហោស១៥០$ហោស

ក៖ ប៉ុន្តែដូចជាល្ខោនយីកេអាយៃអីអ៊ុំចូលចិត្តស្តាប់ដែរទេ?

ខ៖
ខ្ញុំអ្នកលេងអកកេះអូនពីដើមមកដល់ពេលរួចទៅគាត់ស្លាប់ទៅគេបែកគ្នាអស់ទៅគេចែវក្រុមនេះ ក្រុមនោះចឹងទៅណាស់ខ្ញុំអ្នកច្រៀងក៏ឈប់ទៅ

ក៖ បាទ!!អ៊ុំបាទ?

ខ៖ ខ្ញុំមុនមិញប្រាប់ថាអត់ទេណាស់

ក៖ បាទ!!អ៊ុំ?

ខ៖ ប៉ុន្តែតាការពិតខ្ញុំជាអ្នកលេងល្បែង

ក៖
ចុះអ៊ុំគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសាររបស់អ៊ុំគិតថាចេះលេងឧបករណ៍ភ្លេងខ្មែរ ភ្លេងពិនពាត ភ្លេងសៀម ភ្លេងសម័យអីទេអ៊ុំ?

ខ៖ អត់ផងអត់មានទេ

ក៖ អត់មានទេប៉ុន្តែអ៊ុំចេះណាអ៊ុំ?

ខ៖ ខ្ញុំឪរបស់ខ្ញុំនឹងគាត់ជាអ្នកលេងល្ខោន ហើយខ្ញុំនឹងមួយពូជខ្ញុំនឹងបានតែខ្ញុំនឹង

ក៖ ដែរចេះលេង?

ខ៖ បាទ!!បានដើរចេះលេងអកកេះនឹង

ក៖ ចុះអ៊ុំ?

ខ៖ អកកេះពីដើមនឹងធុងទឹកកក់អីនឹងខ្ញុំធ្វើ

ក៖ បាទ!!អ៊ុំ?

ខ៖ ច្នៃដោយខ្លួនឯងនៅផ្ទះខាងលិចហាស

ក៖ អូ!!បាទអ៊ុំ
ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំមានលក្ខណះបែបណាតាំងពីក្មេងរហូតមកដល់ពេលនេះហាស
កាលពីក្មេងផ្ទះយ៉ាងម៉េចហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាសអ៊ុំ?

ខ៖ ពីក្មេងមកនោះគេហៅផ្ទះខ្មោចអូនឯងស្គាល់ហើយ

ក៖ បាទ!!អ៊ុំបាទ?

ខ៖ វាមិនហួសពីរនាបពីរដំបូលទេ

ក៖ បាទ!!

ខ៖

បាទ!!វាបាក់បែកចឹងទៅខ្ញុំក្រនឹងវាត្រូវនឹងផ្ទះនឹងដើរតែមិនស្រួលៗៗនឹងផុងព្រុសឥឡូវនឹង

ក៖ អ៎ូ!!បាទ?

ខ៖ ដល់ឥឡូវនឹងមានលុយ

ក៖ ដល់ពេលឥឡូវនឹងអ៊ុំនមានហើយណាអ៊ុំ?

ខ៖ នេះលុយធីកកាហ្វេនឹងពៅនឹងលុយធីកកាហ្វេនឹង

ក៖ ប៉ុន្តែឥឡូវនឹងផ្ទះរបស់អ៊ុំម៉េចដែរអ៊ុំ?

ខ៖ ឥឡូវនឹងមានផ្ទះប៉ុន្តែភាសាខ្មែរគេហៅថាស្វា

ក៖ ម៉េចចឹងអ៊ុំ?

ខ៖ អូនអត់យល់ទេពាក្យនឹងទាល់តែខ្ញុំប្រាប់អោយអស់នឹង

ក៖ បាទ!!

ខ៖ អូនឯងមើលផ្ទះហោសមួយនឹងក៏ផ្ទះដែរ

ក៖ បាទ!!អ៊ុំ?

ខ៖ មើលខ្ញុំដេកហោសមិនស្វា

ក៖ អ៎ូ!!ចឹងទេ?

ខ៖ ស្វាវាធ្វើផ្ទះហើយវាមិនឡើងដេកលើដំបូល

ក៖ បាទ!!អ៊ុំបាទ?

ខ៖ ដល់ពេលចឹងខ្ញុំហួសពីស្វាទេ ស្វាដែរតែវាចេះដេកហាស

ក៖ បាទ!!ត្រូវហើយអ៊ំ?

ខ៖ ខ្ញុំថាមិនមែនមកពីអានឹងទេមកពីចិត្តគំនិតរបស់យើង

ក៖ បាទ!!អ៊ំបាទ?

ខ៖ អោយមានលុយដាក់ហោប៉ៅទៅបានហើយ

ក៖ បាទ!!អ៊ំបាទ?

ខ៖ ចង់ថាម៉េចថាចុះ

ក៖ បាទ ចុះផ្ទះរបស់អ៊ំនឹងអ៊ំជាអ្នកសាងសងដោយខ្លួនឯង រឺមួយក៏អ៊ំជួលគេធ្វើដែរអ៊ំ?

ខ៖ ខ្ញុំជួលអូន

ក៖ ប៉ុន្តែអ៊ំចេះធ្វើផ្ទះទេអ៊ំ?

ខ៖ អត់ទេតែរោងគោនឹងមិនចេះប្រកផង

ក៖ ប៉ុន្តែអ៊ំមានដឹងថាគេធ្វើផ្ទះនឹងគេប្រើឧបករណ៍អីសំរាប់សាងសងផ្ទះទេអ៊ំ?

ខ៖ មានដែក

ក៖ គេប្រើដែកណាអ៊ំ?

ខ៖ បាទ!!នឹងហើយគេប្រើដែក អានោះឈើ

ក៖ អូ៎!!បាទ ចុះអ៊ំគិតថាជំនាញអីដែរអ៊ំចេះស្ទាត់ជំនាញដែរអ៊ំ
ដែរអ៊ំគិតថាអ៊ំអាចធ្វើបានជាជំនាញតែម្តងនឹងហាស?

ខ៖ ជំនាញខ្ញុំសមុទ្រក៏បាន ទន្លេក៏បាន បឹងក៏បាន ស្ទឹងក៏បានដែរខ្ញុំរកត្រី

ក៖ អូ៎!!បាទអ៊ំបាទ?

ខ៖ នេសាទហាសអូនណាស់

ក៖ ចឹងអ៊ំជំនាញខាងនេសាទណាអ៊ំ?

ខ៖ បាទ!!

ក៖ ចុះឪពុកម្តាយរបស់អ៊ុំធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំទេដូចថាលក្ខណៈវេញវល្លិ៍ក្ងរស្ករត្នោត?

ខ៖ អត់ចេះទេ អ៊ូ!!បើត្នោតខ្ញុំចេះស្រុកខ្មែរអត់មាននរណាគេចេះធ្វើទេ
នៅស្រុកបារាំងអាមេរិចក៏អត់ចេះ ធ្វើដែរខ្ញុំចេះ

ក៖ អ៊ូ!!

ខ៖ បាទ!!ខ្ញុំចេះខុសគេអូនចង់ស្ករអីក៏បានៗខ្ញុំធានាធ្វើអោយ

ក៖ ពីមុនអ៊ុំធ្លាប់ធ្វើហោសអ៊ុំ?

ខ៖ នៅអាពតនៅសម័យអាពតគេអោយខ្ញុំឡើងត្នោត បើមិនចេះគេយកទៅវៃចោល

ក៖ ចឹងមានន័យថាអ៊ុំចេះជំនាញឡើងត្នោតទៀត?

ខ៖ គ្មាននរណាគេចេះធ្វើទេស្ករខ្ញុំ

ក៖ អ៊ូ!!ឡូយហាសណាអ៊ុំ?

ខ៖ បាទ!!

ក៖ ប៉ុន្តែអ៊ុំឥឡូវនឹងម៉េចបានអ៊ុំអត់ធ្វើចឹងអ៊ុំ?

ខ៖ ឆ្អែតហើយអូនមួយថ្ងៃ៧០ដើមហាស

ក៖ អ៊ូ!!ច្រើនណាស់អ៊ុំ?

ខ៖ ឡើងមួយថ្ងៃ៧០ដើមអត់គិតស្នូលផងពាក្យថាស្នូលៗនឹង
ដូចថាដើមពីរជាប់គ្នាអីចឹងនឹង

ក៖ បាទ!!អ៊ុំគេគិតមួយដើម?

ខ៖ គេបោះស្នូលទៅចេះ

ក៖ អ៊ូ!!យើងបោះនៅលើណុងតែម្តងហោសអ៊ុំ?

ខ៖ បាទ!!បោះនៅលើចុងនឹងបោះទៅអានោះមួយទៀត បោះអាសីមួយដើមចឹងទៅ

កៈ បាទ!!

ខៈ ដាក់អាណុងទៅមួយដើមទៀត

កៈ អូ៎!!ចឹង?

ខៈ បើមានទៅណោះទៀតចឹងបោះទៅចឹងទៀតទៅ

កៈ អ៊ុំអត់ខ្លាចទេណាអ៊ុំ?

ខៈ អើរបើយើងនៅនេះបបរ៣វែកគ្រាប់អង្ករប៉ុននេះអូនអើយ
តែដល់ទៅនោះគេអោយយើងហូបគ្រប់ គ្រាន់ចឹងទៅគិតថាបើងាប់រឺក៏ជាបានឆ្អែតវិញ

កៈ បាទ!!អ៊ុំ
ចុះអ៊ុំអាចគិតថាអ៊ុំប្រាប់ខ្ញុំបានទេដូចជាការលំបាករបស់អ៊ុំតាំងពីក្មេងរហូតមកដល់ពេល
នេះ ហាសដូចថាពីក្មេងអ៊ុំមានការលំបាកអីគេខ្លះដែរចឹងហាសអ៊ុំ?

ខៈ លំបាកពីដើមមកនឹងនោះខ្ញុំដូចថាឥឡូវនឹងខ្ញុំនិយាយកាត់ៗតែម្ដងចុះណាស់

កៈ បាទ!!អ៊ុំបាទ?

ខៈ ខ្ញុំវាគ្មានដែរបានស្រណុកទេមកដល់ឥឡូវនឹងក៏ខ្ញុំវាមិនទាន់ដែរស្រណុកដែរ

កៈ បាទ!!អ៊ុំ?

ខៈ ខ្ញុំនៅគិតគួរដូចថានៅកូនចៅរបស់ខ្ញុំវាមានមែនតែកូនវាអត់
សួរថាម៉េចបានវាអត់បើអោយវាទៅ ១០ម៉ឺនអីវាអស់រលីងហើយនឹង

កៈ អូ៎!!១០ម៉ឺនដុល្លាហោសអ៊ុំ?

ខៈ ទេមិនដឹងថា១០ម៉ឺនអី១០ម៉ឺនអាគេអត់ចាយនឹង

កៈ ប៉ុន្តែអ៊ុំគិតថាកាលពីជំនាន់លុនណុលអ៊ុំគិតថាអ៊ុំមានការលំបាកអីទេអ៊ុំ?

ខៈ លំបាកខ្លាំងហាសអានឹងអូន
ពីព្រោះណាមួយគេចាប់ទាហ៊ានឪពុកខ្ញុំកំពុងពេញទាហ៊ាន

កៈ ប៉ុន្តែជំនាន់ពលពតរឺមួយក៏ជំនាន់លុនណុលអ៊ុំ?

ខ៖ នៅជំនាន់លុនណុល

ក៖ លុនណុលហោសអ៊ុំ?

ខ៖ បាទ!!ចាប់ទាហ៊ាន
ពេលចាប់ទាហ៊ានហើយទៅរកត្រីទៀតហើយអានឹងគេថាចុះទឹកក្រពើ
ឡើងទៅលើខ្លាហាស

ក៖ បាទ!!អ៊ុំត្រូវ?

ខ៖ ដល់ពេលដែរឡើងមកលើនឹងគេចាប់ទាហ៊ាន

ក៖ បាទ!!

ខ៖ ចុះទៅរកត្រីនឹងធ្វើនេសាទនឹងទៅដល់នោះអាពតបាញ់ទៀត

ក៖ អូ៎!!

ខ៖
យើងទៅរកនៅក្នុងបឹងនៅអីនឹងលួចចូលលូនទៅរកនឹងអាពតបាញទៀតបាញ់មិនលេងៗ
ៗទេ បាញ់១០០ទៅ២០០អីចឹងនៅប្រវែងៗៗនឹងនៅគល់ចេកអីនឹងឈរមួយកន្លែងនឹង
ផ្លូវវាមានតែមួយចឹង

ក៖ សុតចឹងទៅ?

ខ៖ ដាក់មួយពោងចឹងទៅ

ក៖ ដាកនៅនឹងចឹងទៅ?

ខ៖ ដាក់មួយពោងដឹងតែងាប់ហើយមិនព្រមរកកន្លែងក្រាប់ទៀតហាសស្មៅត្រឹមៗៗនេះ

ក៖ បាទ!!

ខ៖ ក្រាប់ទៅនៅព្រៃនឹងទៅស្មៅខ្ញុំនឹងឪខ្ញុំនេះគាត់ក្រាប់នៅនឹងទៅ

ក៖ អូ៎!!បាទអ៊ុំ?

ខ៖
ទាល់តែស្ងាត់អស់ចឹងទៅគេទៅអស់ចឹងទៅរថគ្រោះទៅចឹងទៅបាននាំគ្នាដើបហើយមកបានរស់

ក៖ បាទ!!អ៊ុំ ចុះគិតថានៅជំនាន់ពលពតអ៊ុំគិតថាធ្លាប់មានជួបការលំបាកអីគេដែរទៅអ៊ុំ?

ខ៖ អើរលំបាកច្រើនមែនទែនរត់ពីនេះ រត់ពីភូមិនេះទៅនៅវត្តនេះ

ក៖ បាទ!!អ៊ុំ?

ខ៖
រត់ពីវត្តនឹងទៅនៅក្នុងព្រៃម្តងទៀតគេទំលាក់គ្រាប់បែកនឹងច្រើនពេកនឹងរតើទៅនៅព្រៃអាសី រត់ពីព្រៃអាសីទៅនៅអីពោធ៍ចិនតុងហោសនៅឯព្រៃកព្រីង

ក៖ បាទ!!អ៊ុំនៅចំការព្រីងហីអ៊ុំ?

ខ៖ នៅព្រៃកព្រីង

ក៖ អូ៎!!

ខ៖ ពីដើមគេហៅព្រៃកព្រីកន្លែងកាប់គោហាស

ក៖ បាទ!!បាទអ៊ុំ ចុះពលពតកាលណុងគេអោយអ៊ុំធ្វើអីគេដែរទៅ?

ខ៖ ពលពតមកសម័យអាពតនេះខ្ញុំខ្ញុំចូលមកគេអោយខ្ញុំធ្វើស្រែធ្វើចំការ
មុនដំបូងគេអោយយើងធ្វើចឹងទៅណាស់

ក៖ បាទ!!អ៊ុំបាទ?

ខ៖ តែដល់ពេលខ្ញុំប៉ិនរត់មកផ្ទះពេក
គេអោយខ្ញុំទៅឡើងត្នោតនៅវត្តពព្រេងនៅលិចហោស

ក៖ ប៉ុន្តែដូចជាអ៊ុំគេអោយជំលាសទៅណាដែរអ៊ុំពេលណុង?

ខ៖ ខ្ញុំគេអត់អោយជំលាសផង

ក៖ គេអោយអ៊ុំនៅនឹង?

ខ៖ ឪពុកខ្ញុំនឹងគាត់ចេះរកត្រី

ក៖ បាទ!!

ខ៖ ដល់ពេលចឹងគេអោយឪពុករបស់ខ្ញុំរកត្រីអោយកងទ័ពបាទ

ក៖ អូ៎!!ប៉ុន្តែក្រុមគ្រួសាររបស់អ៊ុំនៅជុំគ្នាចឹងហោសអ៊ុំ?

ខ៖ បាទ!!

ក៖ រឺមួយក៏បែកគ្នាខ្លះដែរអ៊ុំ?

ខ៖ បែកឪពុករបស់ខ្ញុំនឹងនៅនេះនៅក្នុងបឹងនេះ
ហើយម៉ែរបស់ខ្ញុំនឹងនៅភូមិនោះនៅវត្តនោះ

ក៖ បាទ!!

ខ៖
ព្រែកថ្លឹងខ្ញុំនៅយុវជនយុវនារីវត្តចំការខ្សាច់ដល់ហើយគេដូរខ្ញុំបញ្ជូនខ្ញុំទៅឡើងត្នោតនៅវត្ត
ពព្រេង

ក៖ អូ៎!!ចឹងណាអ៊ុំណា
ចុះអ៊ុំគិតថាជំនាន់ធ្វើទាហ៊ានវិញហាសជំនាន់ប៉ែតជាងហាសពេលណុងអ៊ុំបានទៅ
ធ្វើជាទាហ៊ានដែរតើហីអ៊ុំ?

ខ៖ ខ្ញុំកំសត់ណាស់អូនអើយ

ក៖ អូ៎!!ចឹង?

ខ៖ ពេលនេះអត់បាននៅផ្ទះទេមិនខុសពីលុនណុលទេខ្ញុំនិយាយចឹងតែម្តង

ក៖ កាលពីជំនាន់ណុងហោសអ៊ុំ?

ខ៖ នេះមើលមួយចំហៀងនឹងហាស

ក៖ អូ៎!!មួយនឹងគេធ្វើអីគេដែរអ៊ុំ?

ខ៖ ទាល់តែចឹងបានបានមកដល់ឥឡូវ

កៈ អូ៎!!

ខៈ ខ្ញុំប្រាប់ថាមិនខុសពីលុនណុលទេអត់មានយុវជនក្មេងៗៗណាតាមក្រុមរឺមួយក៏អីទេអូនឯងបានថតដាក់ទៅវាបានលឺហើយ

កៈ
បាទ!!ចុះអ៊ុំគិតថាអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបម៉េចដែរអ៊ុំជំនះវាដោយរបៀបម៉េចដែរ?

ខៈ ចឹងជំនះដល់ពេលថ្ងៃក្រោយឡើងខ្ញុំចាញ់ដែរ វារត់លែងរួចហើយ

កៈ បាទ!!អ៊ុំបាទ?

ខៈ
កាលណារត់ម្តងទៅគេចាប់បានចឹងទៅយើងមានលុយចឹងទៅមួយជីអោយចឹងទៅវាចាប់ខ្ញុំចឹងទៅ វាលែងខ្ញុំចឹងទៅវាទៅចាប់អាអូនឯងម្តងចឹងទៅ

កៈ បាទ!!អ៊ុំបាទ?

ខៈ អោយអូនឯងទៅជំនួស

កៈ ចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាសប្បាយនៅក្នុងជីវិតរបស់អ៊ុំ?

ខៈ ជីវិតនឹងមកឥឡូវនឹងបានមកសប្បាយហើយ
នេះទើបតែមកបានសប្បាយនឹងតែវាសប្បាយមែនតែ វានៅក្នុងការរឹតលើសពីមុនទៀតលើសពីកាលនឹងទៀតព្រោះកូនវាធ្វើបាបនឹងប្រពន្ធ

កៈ ចឹងហោសអ៊ុំ?

ខៈ ប្រពន្ធនេះប្រពន្ធខ្ញុំក្រោយ

កៈ អូ៎!!

ខៈ ប្រពន្ធខ្ញុំនៅនោះ

កៈ បាទ!!អ៊ុំបាទ?

ខៈ ប្រពន្ធយកលក់ខ្ញុំឡើងឆ្កួតលីលីហើយនឹង ប្រាប់ថាខ្ញុំនិយាយអីនឹងមិនសូវការចេងចាំទេ

កៈ បាទអ៊ុំ ចុះអ៊ុំកាលពីក្មេងអ៊ុំធ្លាប់មានក្ដីស្រម៉ៃថាពេលដែរធំឡើងនឹងអ៊ុំចង់ធ្វើអីទេ?

ខៈ ធំឡើងនឹងអត់ចង់ធ្វើអីទេចង់ធ្វើស្រែហើយនឹងឃ្វាលគោ

កៈ ចឹងហោសអ៊ុំណា?

ខៈ
បាទ!!ពីព្រោះយើងខ្ញុំនឹកឃើញថាបានថាចឹងពីព្រោះខ្ញុំជាជីវិតកូនអ្នកក្រហើយនឹងខ្ញុំនៅស្រែ

កៈ បាទ!!អ៊ុំ?

ខៈ ដល់ពេលចឹងខ្ញុំចង់ធ្វើតែប៉ុណ្ណឹង

កៈ អូ៎!!ចុះអ៊ុំគិតថាបើសិនជាចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗៗរបស់អ៊ុំ
អ៊ុំចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរអ៊ុំ?

ខៈ ខ្ញុំផ្ដែផ្ដាំថាម៉េចទេនេះ

កៈ ចង់ថាលក្ខណៈថា?

ខៈ បើប្រាប់ថាសូម្បីតែកូនឯងនឹងក៏អត់កើតដែរចុះទៅផ្ដែទៅគេធ្វើអីទៀត

កៈ អូ៎!!ចឹងហោសអ៊ុំ?

ខៈ បាទ!!ខ្ញុំចង់អោយមនុស្សនឹងល្អអោយបានតែពាក់កណ្ដាលខ្ញុំ

កៈ អូ៎!!បាទអ៊ុំ?

ខៈ ហើយនឹងលោកអាចារ្យ
សូមផ្ដាំទៅលោកអាចារ្យផងនិយាយអោយលឺបន្ដិចថាលោកអាចារ្យវត្ត
ហើយនឹងលោកនឹងកុំអោយវាហួសសម័យចឹងពេក
វាហួសហើយលោកក៏វាហួសអាចារ្យក៏វាហួសដែរ ឥឡូវនឹង

កៈ ម៉េចចឹងអ៊ុំ?

ខៈ បាទ!!សូម្បីតែបិណ្ឌបាទគេមន្ដទៅ១០០អង្គមានដល់ទៅ១២០
ចូលគេមានរបងគេគេមានអីត្រឹមត្រូវ វត្តអីចឹងហាស

កៈ បាទអុំបាទ?

ខៈ អត់ចូលតាមរបងត្រឹមត្រូវទេផ្លោសបងចូលទៀត

កៈ អើរ?

ខៈ ហីអូនឯងបិណ្ឌបាទនៅកន្លែងម៉ុងអីនឹងសុទ្ធតែខ្ញុំយាមនៅណុង

កៈ លោកផ្លោសហោសអុំ?

ខៈ បាទ!!នោះស្បួងជីពរនៅទេ នោះស្បួងលោកក្លែងក្លាយនឹងលោកស្រាត

កៈ អូ!!ចឹង?

ខៈ នៅកន្លែងប៉ុស្ដិ៍អីនឹងតែម្ដងនឹង

កៈ លោកក្លែងក្លាយហោស?

ខៈ បាទ!!ខ្ញុំអត់នៅខ្ញុំនៅចាប់បានខ្ញុំវៃទាល់តែងាប់នឹង

កៈ បាទ!!អុំបាទ?

ខៈ
អើរចឹងបានថាពិបាកធ្វើបុណ្យណាស់អាចារ្យឥឡូវនឹងយកទៅដូចថាមានកូន៥នាក់ចឹងហាស តិចទៀតមកឥឡូវហើយនឹងចាំមើលថតទុកទៅ

កៈ អាចារ្យហោសអុំ?

ខៈ នឹងហើយៗ តិចទៀតមកឃើញហើយមានតាំងធុង
មានតាំងស្រាក់អីនឹងមានមួយកំផ្លេ

កៈ អូ!!បាទអុំ?

ខៈ អូ!!អូនអាចារ្យចឹង

កៈ មានអីផ្សេងដែរចង់ផ្ដែផ្ដាំអីទៀតទេអុំ?

ខៈ ចង់ផ្ដាំថាកុំអោយវាមានចឹងទៀតប្រាប់ប្រជាជនខ្មែរយើងនឹង

កៈ បាទៗ!!អុំបាទ?

ខ៖ បាទ!!

ក៖
បាទចឹងជាចុងក្រោយខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំបានពិភាក្សាជាមួយអ៊ុំដែរទាក់ទងពីប្រវត្តិរបស់អ៊ុំ
ហើយពេលក្រោយដែរខ្ញុំបានមកជួបអ៊ុំវិញយកជាការសំភាសន៍មួយនឹងដូចជាឌីសមួយនឹងយកអោយអ៊ុំដើម្បីអោយកូនចៅរបស់អ៊ុំបានស្តាប់ នឹងបានដឹងចឹងហាសអ៊ុំ?

ខ៖ បាទ!!នឹងហើយ

ក៖ បាទ!!អរគុណច្រើនអ៊ុំ៕៕